ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ១០៦៥ ទី.សណ.ទឃ

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**
**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ ៖** ករណីគោរពស្នើសុំការពិនិត្យ និងសម្រេចលើឯកសារទស្សនទានសម្រាប់រៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០)។

**យោង ៖** -លិខិតលេខ២៣១ លស/គ.ជ.អ.ប ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

-លិខិតលេខ៦៣០ ខន/០២០ សជណ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនសម្តេចក្រឡាហោមមេត្តាជ្រាបថា រាជរដ្ឋាភិបាលសម្រេចយល់ព្រមលើឯកសារទស្សនទានសម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ដូចមានក្នុងឯកសារភ្ជាប់ជាមួយ។

សេចក្តីដូចបានជម្រាបជូនខាងលើសូមសម្តេចក្រឡាហោមមេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

**ឧ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**កែន សត្ថា**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

(គ.ជ.អ.ប.)

# ឯកសារទស្សនទាន

## សម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ

## តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២

## (២០២១ - ២០៣០)

ខែវិច្ឆិកា ឆ្នាំ២០២០

## I. សេចក្តីផ្តើម

រាជរដ្ឋាភិបាលបានចាត់ទុកកំណែទម្រង់អភិបាលកិច្ចគឺជាកិច្ចការដ៏មានសារសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីឈានឆ្ពោះទៅសម្រេចឱ្យបាននូវឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបាន និងកំពុងធ្វើទំនើបកម្មយ៉ាងទូលំទូលាយ និងស៊ីជម្រៅនូវប្រព័ន្ធអភិបាលកិច្ចតាមរយៈកម្មវិធីកំណែទម្រង់នានា រួមមានកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់តាមវិស័យនានា។

កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានចាប់ផ្តើមក្នុងដំណាក់កាលដំបូងជាប្រវត្តិសាស្ត្រតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសនាឆ្នាំ២០០២។ ផ្អែកតាមបទពិសោធន៍ និងភាពជោគជ័យនៃការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានសម្រេចពង្រីកវិសាលភាពនៃកំណែទម្រង់នេះទៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេសនាឆ្នាំ២០០៩។ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការទាំងនេះ ត្រូវបានកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តច្បាប់រៀបចំអង្គការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០-២០២០)។ កម្មវិធីជាតិនេះនឹងត្រូវបញ្ចប់នៅដំណាច់ឆ្នាំ២០២០នេះ ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងការបង្កើតឡើងនូវរចនាសម្ព័ន្ធនិងប្រព័ន្ធអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារក្នុងការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាន ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការផ្ទេរបុគ្គលិកនិងការកសាងសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងតួនាទីស្ត្រីក្នុងដំណើរការអភិបាលកិច្ចមានភាពល្អប្រសើរឡើងជាលំដាប់ ព្រមទាំងការផ្តល់សេវាសាធារណៈមានការឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះនានា។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តកម្មវិធីជាតិនេះបានជួបនូវបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលនាំឱ្យមិនអាចសម្រេចបានពេញលេញនូវចក្ខុវិស័យគោលបំណង និងគោលដៅនៃកម្មវិធីជាតិនេះ។

ក្នុងគោលបំណងបន្តដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ បន្តអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការឱ្យកាន់តែស៊ីជម្រៅ និងបន្តចូលរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ រាជរដ្ឋាភិបាលសម្រេចរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ សម្រាប់រយៈពេល១០ឆ្នាំគឺចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។

ឯកសារទស្សនទាននេះ គឺជាឯកសារសម្រាប់តម្រង់ទិសដល់ការរៀបចំតាក់តែងកម្មវិធីជាតិដំណាក់កាលទី២។ ឯកសារទស្សនទាននេះត្រូវបានរៀបចំឡើង ដោយមានការពិភាក្សា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយក្រសួង ស្ថាប័នជាសមាជិក គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ព្រមទាំងបានដាក់ឱ្យពិភាក្សា និងពិគ្រោះយោបល់ក្នុងសិក្ខាសាលាជាតិមុននឹងដាក់ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។ ឯកសារទស្សនទាននេះកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រសម្រាប់រៀបចំកម្មវិធីជាតិ សមាសភាគស្នូលនានានៃកម្មវិធីជាតិដែលរួមមានសមិទ្ធផលសំខាន់ៗនិងកិច្ចការជាអាទិភាពនានា ព្រមទាំងបែបផែននៃការគ្រប់គ្រង និងការអនុវត្តកម្មវិធីដំណាក់កាលទី២ (២០២១-២០៣០)។

## II. សមិទ្ធផល និងបញ្ហាប្រឈម

### ១. សមិទ្ធផល

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដំណាក់កាលទី១ រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលធំៗដូចខាងក្រោម៖

– បង្កើតបាននូវមូលដ្ឋានគ្រឹះសំខាន់ៗនៃរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យនៅគ្រប់កម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងនោះរួមមាន ការបង្កើតក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរយៈការបោះឆ្នោត ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រង ព្រមទាំងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួមមាន នីតិវិធីរៀបចំកិច្ចប្រជុំនិងការធ្វើសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សា នីតិវិធីនៃការរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុមប្រឹក្សា និងនីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុ ដើម្បីបង្កលក្ខណៈឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសមធម៌។ រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំឡើងវិញដោយផ្អែកតាមគោលការណ៍រដ្ឋបាលឯកភាព តាមរយៈធ្វើសមាហរណកម្មការិយាល័យជំនាញនានារបស់ក្រសួងចំនួន២០ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីនេះនាឆ្នាំ២០១៩។

– បានរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្ដល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនដែលត្រូវបានផ្ទេរទៅឱ្យក្នុងចំនួនប្រមាណជាង ៤០.០០០នាក់។ ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកទាំងនោះអំពីការទទួលខុសត្រូវ តួនាទី ភារកិច្ច និងនីតិវិធីអនុវត្តការងារក៏ត្រូវបានផ្ដល់ តាមរយៈវគ្គបណ្ដុះបណ្ដាលខ្លីៗ សិក្ខាសាលា និងការហ្វឹកហាត់ការងារជាក់ស្ដែង។ ទន្ទឹមនោះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏ត្រូវបានបង្កើតឡើងដើម្បីផ្ដល់សេវាអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

– បានផ្ទេរមុខងារចំនួន៥៥ ក្នុងវិស័យចំនួន២០ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានផ្ទេរមុខងារក្នុងវិស័យសង្គមកិច្ច និងសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមគោលការណ៍

វិមជ្ឈការ ដើម្បីបង្កើតការផ្តល់សេវាឱ្យកៀកជិតប្រជាពលរដ្ឋនៅមូលដ្ឋាន និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់មួយចំនួនពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

– បង្កើតបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការហិរញ្ញវត្ថុដូចជា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក ដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានបង្កើតឡើង ដែលរួមមាន ប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌដូចជា មូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដូចជា ប្រព័ន្ធផ្ទេរមូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ព្រមទាំងប្រព័ន្ធចែករំលែកចំណូលសារពើពន្ធរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងក្របខ័ណ្ឌនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងភាពជោគជ័យនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានបង្កើនការផ្ទេរថវិការដ្ឋជារៀងរាល់ឆ្នាំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរហូតមកទល់ឆ្នាំ២០២០នេះ ថវិកានេះមានចំនួនសរុបប្រមាណជាង **៣.៨០០លានដុល្លារ**សម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ។

– បង្កើតបាននូវប្រព័ន្ធកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំ ស្របទៅតាមចរិតលក្ខណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាដល់ការប្រើប្រាស់ធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌។

– បង្កើតបាននូវយន្តការគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលរួមមានដូចជាការបង្កើតការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស ដើម្បីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានាក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងការបំពេញមុខងារ និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតក្របខ័ណ្ឌការងារគណនេយ្យភាពសង្គមក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិល ដើម្បីផ្តល់ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាឃុំ សង្កាត់ និងអង្គភាពជំនាញនានានៅតាមមូលដ្ឋាន ព្រមទាំងដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការចូលរួមតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់កែលម្អលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវាកម្មនៅមូលដ្ឋានមួយចំនួនដូចជាសាលាបឋមសិក្សា និងមណ្ឌលសុខភាពជាដើម។

– ផ្អែកតាមរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិបានផ្តល់សេវារដ្ឋបាលប្រមាណជាង៦០០ប្រភេទ ព្រមទាំងបានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនិងអនុវត្ត

គម្រោងសេវាសង្គមប្រមាណជាង២.០០០គម្រោងក្នុងមួយឆ្នាំៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងមូលដ្ឋាន ដែលជាការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

– បានបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់ដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្រោមក្របខ័ណ្ឌនៃយន្តការនេះ គ.ជ.អ.ប. បានកៀរគរការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាដល់ការអនុវត្តកម្មវិធីកំណែទម្រង់នេះ។ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់គ.ជ.អ.ប. ក្រសួង ស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធចំនួន២៣ និងរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានសមាជិកសរុបចំនួន ១៥.៦៨៦រូប ត្រូវបានបង្កើតឡើងដើម្បីធ្វើជាយន្តការតំណាងឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសសម្រាប់ការពារ គាំទ្រ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

– បានរៀបចំលិខិតបទដ្ឋានគតិយុត្តនានាដែលឆ្លើយតបនឹងយេនឌ័រ និងលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ ជាពិសេសបានបង្កើតនូវគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានធ្វើសវនកម្មយេនឌ័រក្នុងប្រព័ន្ធគ្រប់គ្រងការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមជូនថ្នាក់ដឹកនាំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗបានបង្កើតនូវគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ក.ស.ក) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (គ.ក.ន.ក) ដែលជាយន្តការដ៏មានសារសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាអាទិភាពរបស់ស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះ។

## ២. បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលធំៗខាងលើនេះ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តដោះស្រាយ ដូចខាងក្រោម៖

– កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាគោលនយោបាយដ៏មានសារសំខាន់របស់រាជរដ្ឋាភិបាលដែលបានដាក់ឱ្យអនុវត្តជិត២ទសវត្សមកហើយ ក៏ប៉ុន្តែការយល់ដឹងរបស់អ្នកពាក់ព័ន្ធនានាទាំងស្ថាប័នសាធារណៈ សង្គមស៊ីវិល និងសាធារណជនអំពីកំណែទម្រង់នេះនៅមានកម្រិត និងមានការយល់ឃើញនិងបកស្រាយផ្សេងគ្នាៗអំពីចក្ខុវិស័យ និងគោលបំណងនៃកំណែទម្រង់នេះ។

– រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានរៀបចំឡើងវិញ និងកែសម្រួលជាបណ្តើរៗនាពេលកន្លងមក ក៏ប៉ុន្តែរចនាសម្ព័ន្ធ និងប្រព័ន្ធទាំងនេះនៅមិនទាន់មាន

លក្ខណៈសមស្របតាមចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលមានលក្ខណៈជាទីក្រុងធំ(រាជធានីភ្នំពេញ) ទីប្រជុំជន(ក្រុង សង្កាត់) និងតំបន់ជនបទ(ស្រុក ឃុំ) ព្រមទាំងផ្អែកទៅតាមលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ចសង្គមខុសៗគ្នានៅឡើយ។

– ផ្អែកតាមកម្មវិធីជាតិដំណាក់កាលទី១ រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំឱ្យក្លាយទៅជារដ្ឋបាលមូលដ្ឋានដែលមានតួនាទីសំខាន់ក្នុងការផ្តល់សេវាសាធារណៈចាំបាច់មួយចំនួនដោយផ្ទាល់ជូនប្រជាពលរដ្ឋ និងរដ្ឋបាលខេត្តជារដ្ឋបាលថ្នាក់តំបន់ដែលមានតួនាទីសំខាន់ក្នុងការគាំទ្រ តាមដាន ត្រួតពិនិត្យ អភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលមូលដ្ឋាន និងផ្តល់សេវាសាធារណៈនិងគម្រោងវិនិយោគធំៗដែលរដ្ឋបាលមូលដ្ឋានមិនមានលទ្ធភាពអនុវត្ត។ ទោះបីយ៉ាងនេះក្តី ការសិក្សាអំពីការរៀបចំរដ្ឋបាលខេត្តឱ្យក្លាយទៅជារដ្ឋបាលតំបន់នៅមិនទាន់បានអនុវត្តនៅឡើយ។

– ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់បំពេញតួនាទីពេញលេញជាអង្គធ្វើសេចក្តីសម្រេចចិត្តលើផែនការ និងថវិការបស់ខ្លួន ព្រមទាំងបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋក្នុងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ពាក់ព័ន្ធនឹងបញ្ហានេះ ទាមទារឱ្យមានការកែលម្អកិច្ចដំណើរការពិនិត្យ អនុម័ត និងការតាមដានត្រួតពិនិត្យលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា ព្រមទាំងការកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តតួនាទីទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព។

– បើទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម និងការបង្កើតការិយាល័យប្រជាពលរដ្ឋក៏ដោយ ក៏ប្រជាពលរដ្ឋនៅមិនទាន់យល់ដឹងច្បាស់លាស់អំពីសិទ្ធិរបស់ខ្លួនក្នុងការជំរុញឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះខ្លួនឡើយ។

– បើទោះបីជាមានការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយក៏ដោយ ក៏ការបែងចែកសិទ្ធិអំណាច តួនាទី ភារកិច្ច និងការទទួលខុសត្រូវលើការអនុវត្តមុខងារផ្តល់សេវាសាធារណៈចាំបាច់មួយចំនួនរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានភាពមិនទាន់ច្បាស់លាស់ ព្រមទាំងមិនទាន់មានភាពសមស្របទៅនឹងគោលនយោបាយវិមជ្ឈការក្នុងការបង្វិតការផ្តល់សេវាសាធារណៈទៅកៀកជិតជាមួយប្រជាពលរដ្ឋ។ ប្រការនេះធ្វើឱ្យប្រជាពលរដ្ឋនៅតែជួបការលំបាកក្នុងការទទួលបាននូវសេវាសាធារណៈចាំបាច់មួយចំនួន។

– ការគ្រប់គ្រង និងការប្រើប្រាស់ធនធានឆន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុកនៅមិនទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ដោយហេតុថាស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលទាំងនេះនៅមានកម្រិតដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ប្រការនេះចាំបាច់ត្រូវមានការពិនិត្យ និងកែសម្រួលនូវលិខិតបទដ្ឋានគតិយុត្តទាំងនេះដើម្បីផ្តល់ស្វ័យភាព រួមជាមួយនឹងវិធានការដើម្បីពង្រឹងភាពជាអ្នកដឹកនាំរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានឆន្ទានុសិទ្ធិរបស់ខ្លួនប្រកបដោយភាពត្រឹមត្រូវ សមស្រប និងមានប្រសិទ្ធភាព។

– ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការផ្ទេរមុខងារមួយចំនួនទៅឱ្យរដ្ឋបាលក្រុង

ស្រុក ខណ្ឌក៏ដោយ ក៏ការផ្ទេរបុគ្គលិក ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់អនុវត្តមុខងារទាំងនេះ ពុំទាន់មានលក្ខណៈសមស្របតាមចំនួននិងទំហំមុខងារដែលបានផ្ទេរ ព្រមទាំងពុំទាន់មានដំណើរការដោយរលូននៅឡើយ។

– ការគ្រប់គ្រង និងការអនុវត្តមុខងារផ្តល់សេវាដែលត្រូវរ៉ាប់រងដោយកម្រៃសេវាដែលប្រមូលបានពីអ្នកប្រើប្រាស់សេវាក៏នៅជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន។ ជាក់ស្តែង មុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុកនៅមិនទាន់អាចអនុវត្តបានល្អនៅឡើយទេ ដែលតម្រូវឱ្យមានការពង្រឹងយន្តការគាំទ្រ ការពង្រឹងសមត្ថភាពនិងការទទួលខុសត្រូវរបស់រដ្ឋបាលទាំងនោះបន្ថែមទៀត។

– ទោះបីធនធានហិរញ្ញវត្ថុដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ក៏ទំហំធនធាននេះនៅមិនទាន់មានលក្ខណៈសមស្របទៅនឹងមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឡើយ។ ប្រការនេះ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុឱ្យមានទំហំសមស្រប ព្រមទាំងពិនិត្យ និងកែសម្រួលឡើងវិញនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយសមធម៌សំដៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។

– ទោះបីប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបណ្តើរៗក៏ដោយ ក៏សមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ។ បុគ្គលិកជាច្រើនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់យល់ដឹងច្បាស់លាស់អំពីមុខងារនិងការទទួលខុសត្រូវរបស់ខ្លួន មិនទាន់ទទួលបានការបណ្តុះបណ្តាលជំនាញជាក់លាក់ និងពុំទាន់មានការជំរុញលើកទឹកចិត្ត ឬចាត់វិធានការខាងវិន័យឱ្យបានម៉ឺងម៉ាត់ក្នុងការបំពេញការងាររបស់បុគ្គលិក។

– បច្ចុប្បន្ននេះ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័សដែលត្រូវបាន និងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធគ្រប់គ្រងការងារ ការចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទងជាសាធារណៈ។ ទោះយ៉ាងនេះក្តី រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារភាគច្រើនរបស់ខ្លួននៅតែផ្អែកលើប្រព័ន្ធរដ្ឋបាលប្រើប្រាស់ក្រដាសស្នាម និងធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋដោយការជួបមុខគ្នាដោយផ្ទាល់ ដែលជាហេតុធ្វើឱ្យការទទួលសេវា និងការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋនៅមានភាពយឺតយ៉ាវ និងមានការលំបាក។ ប្រការនេះ ចាំបាច់ត្រូវជំរុញការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានៅតាមស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

## III. ចក្ខុវិស័យនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០៣០

ផ្នែកនេះនឹងកំណត់អំពីចក្ខុវិស័យនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវសម្រេចឱ្យ

បាននៅឆ្នាំ២០៣០ ឬបន្ទាប់ពីបញ្ចប់ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។ ក្នុងន័យនេះ ផ្នែកនេះនឹងពន្យល់អំពីវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមនានាដូចបានរៀបរាប់នៅក្នុងផ្នែកទីIIខាងលើ និងអំពីការប្រមើលមើលនូវចំណុចដៅរំពឹងទុកចុងក្រោយនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវកំណត់ក្នុងកម្មវិធីជាតិដំណាក់កាលទី២។

ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល១០ឆ្នាំខាងមុខគឺ ***ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ប្រែក្លាយប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។*** ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ផ្នែកនេះនឹងពិពណ៌នាអំពីប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ រួមមានដូចជាស្ថាប័ន មុខងារ សមត្ថភាព និងប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិដែលត្រូវរៀបចំ និងដាក់ឱ្យអនុវត្តក្នុងរយៈពេល១០ខាងមុខ ដូចខាងក្រោម៖

### ១. រចនាសម្ព័ន្ធ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅឆ្នាំ២០៣០ រចនាសម្ព័ន្ធ មុខងារ និងប្រព័ន្ធទំនាក់ទំនងអន្តរស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗនឹងត្រូវបានរៀបចំកែសម្រួល ដោយផ្តោតលើការពង្រឹងនូវស្វ័យភាព ភាពជាម្ចាស់ ការទទួលខុសត្រូវ និងការបែងចែកនូវខ្សែគណនេយ្យភាពឱ្យបានច្បាស់លាស់។

ការបែងចែកការទទួលខុសត្រូវរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងស្ថាប័នថ្នាក់ជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវកំណត់យ៉ាងច្បាស់លាស់។

ការប្រគល់មុខងារពីក្រសួងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតាមគោលការណ៍ដែលកំណត់ថា **សេវាសាធារណៈនានាត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់ណាដែលអាចមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចខ្ពស់បំផុត និងឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋានបានយ៉ាងល្អប្រសើរ។** ក្រសួងស្ថាប័នថ្នាក់ជាតិនឹងមានការទទួលខុសត្រូវសំខាន់ទៅលើការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដាសេវា ការគាំទ្រ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានការទទួលខុសត្រូវជាចម្បងលើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកលើរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នាពេលបច្ចុប្បន្ន ចាំបាច់ត្រូវរៀបចំកែសម្រួលប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះឱ្យមានលក្ខណៈកាន់តែសមស្រប និងឆ្លើយតបបានទៅនឹងការកើនឡើងនៃតម្រូវការសេវារបស់ប្រជាពលរដ្ឋ និងភាពផ្សេងៗគ្នានៃចរិតលក្ខណៈរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ ជាទូទៅ បណ្តុំសេវានៅតំបន់ទីក្រុងនឹងត្រូវផ្តល់ដោយរដ្ឋបាលដែលមានលក្ខណៈជាទីប្រជុំជន (រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលសង្កាត់)

ដោយឡែក សេវានៅតំបន់ជនបទនឹងត្រូវផ្តល់ដោយរដ្ឋបាលស្រុក ឬរដ្ឋបាលឃុំ។ ក្នុងន័យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗនឹងត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលដូចខាងក្រោម៖

**រដ្ឋបាលរាជធានី៖** រាជរដ្ឋាភិបាលនឹងរៀបចំប្រែក្លាយរដ្ឋបាលរាជធានីភ្នំពេញទៅជា**រដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន** (Metropolitan ទីក្រុងដែលមានប្រជាជនច្រើនកុះករ) ដែលមានប្រព័ន្ធគ្រប់គ្រងខុសពីរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងដទៃទៀត។ ប្រព័ន្ធគ្រប់គ្រងរាជធានីភ្នំពេញ (ទីក្រុងមេត្រូប៉ូលីតែន) នឹងត្រូវរៀបចំស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាពដែលអាចរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគមានលក្ខណៈជាយុទ្ធសាស្ត្រ អាចអនុវត្តនូវគម្រោងវិនិយោគធំៗ ព្រមទាំងអាចសម្របសម្រួលបាននូវការផ្តល់សេវាសាធារណៈនានានៅទូទាំងដែនដីនៃរដ្ឋបាលរាជធានីដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានីរួមមានដូចជា ការរៀបចំផែនការតំបន់ទីប្រជុំជន ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងរាជធានី សេវាដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងចរាចរណ៍ និងមុខងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ព្រមទាំងអនុវត្តមុខងារមួយចំនួនបន្ថែមទៀតពីលើមុខងារដែលបានផ្ទេរទៅឱ្យនាពេលកន្លងមកនេះ។

ផែនការ និងគម្រោងថវិការបស់ខណ្ឌ និងសង្កាត់ក្នុងរាជធានីនឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការ និងគម្រោងថវិការបស់រដ្ឋបាលរាជធានី។ មុខងារផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលដែលមិនទាមទារឱ្យមានការសម្របសម្រួលឆ្លងដែនសមត្ថកិច្ចរបស់ខណ្ឌ ហើយជាមុខងារដែលខណ្ឌអាចគ្រប់គ្រងចាត់ចែង និងអនុវត្តបានប្រកបដោយប្រសិទ្ធភាព នឹងត្រូវធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលខណ្ឌ។ សេវារដ្ឋបាលចាំបាច់មួយចំនួននឹងត្រូវផ្តល់ដោយយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលសង្កាត់។

**រដ្ឋបាលខេត្ត៖** រាជរដ្ឋាភិបាលនឹងរៀបចំប្រែក្លាយរដ្ឋបាលខេត្តទៅជា**រដ្ឋបាលតំបន់**ស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលមានមុខងារសំខាន់ៗពាក់ព័ន្ធការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគជាយុទ្ធសាស្ត្រ ការគាំទ្រ ការសម្របសម្រួល ការត្រួតពិនិត្យនីត្យានុកូលភាព ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន (រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់) និងការអនុវត្តមុខងារធំៗដែលរដ្ឋបាលក្រុង ស្រុកពុំអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព ព្រមទាំងអនុវត្តនូវមុខងារផ្សេងៗទៀតក្នុងនាមជាតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិ។

**រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក៖** រាជរដ្ឋាភិបាលនឹងរៀបចំប្រែក្លាយរដ្ឋបាលក្រុង និងរដ្ឋបាលស្រុកទៅជា**រដ្ឋបាលមូលដ្ឋាន**ដែលមានស្វ័យភាព និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ និងធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្សក្នុងកម្រិតសមស្របមួយផ្អែកតាមការរីកចម្រើននៃផ្នែកនគរូបនីយកម្ម ស្ថានភាពពាណិជ្ជកម្ម និងសក្តានុពលសេដ្ឋកិច្ច។ រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកមានតួនាទី និងការទទួលខុសត្រូវសំខាន់ក្នុងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈភាគច្រើនដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មន្ត្រីជំនាញបច្ចេកទេសភាគច្រើនដែលទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈនឹងត្រូវមកបំពេញការងារនៅរដ្ឋបាលក្រុង និងរដ្ឋបាលស្រុក។

**រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក**នឹងត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ មុខងារ និងការទទួលខុសត្រូវផ្សេងពីគ្នាដោយផ្អែកលើការរីកចម្រើនផ្នែកនគរូបនីយកម្ម ស្ថានភាពពាណិជ្ជកម្ម និងសក្តានុពលសេដ្ឋកិច្ច។ល។ **រដ្ឋបាលក្រុង**នឹងមានការទទួលខុសត្រូវជាអាទិភាពទៅលើការរៀបចំផែនការទីប្រជុំជន និងការគ្រប់គ្រងការផ្តល់សេវាទីប្រជុំជននានារួមមានដូចជា សេវាដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងផ្លូវក្រុង ផ្លូវទីប្រជុំជន បណ្តាញលូបង្ហូរទឹក និងការគ្រប់គ្រងសំរាមសំណល់រឹងជាដើម។ **រដ្ឋបាលស្រុក**នឹងមានការទទួលខុសត្រូវជាអាទិភាពទៅលើការងារកសិកម្ម និងការអភិវឌ្ឍជនបទ រួមទាំងការគ្រប់គ្រងបណ្តាញផ្លូវជនបទ ការផ្គត់ផ្គង់ទឹកស្អាត សេវាអនាម័យជនបទ និងការគ្រប់គ្រងសំរាមសំណល់រឹងជាដើម។

**រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់៖** រាជរដ្ឋាភិបាលនឹងរៀបចំប្រែក្លាយរដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ទៅជា**រដ្ឋបាលមូលដ្ឋាន**ដែលជាកន្លែងសម្រាប់ប្រាស្រ័យទាក់ទងដំបូងគេរបស់ប្រជាពលរដ្ឋជាមួយនឹងស្ថាប័នសាធារណៈ និងមានមុខងារ និងការទទួលខុសត្រូវក្នុងការផ្តល់សេវារដ្ឋបាលដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រៅពីការផ្តល់សេវារដ្ឋបាលមួយចំនួន រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ត្រូវមានការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈដូចជា ការផ្តល់សេវាក្នុងវិស័យសង្គមកិច្ចនៅតាមមូលដ្ឋានមួយចំនួន ព្រមទាំងការទទួលខុសត្រូវលើការអភិវឌ្ឍ និងការថែទាំគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទខ្នាតតូចមួយចំនួន។ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់នៅតែមានការទទួលខុសត្រូវលើការរៀបចំផែនការ និងការអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋានក្នុងក្របខ័ណ្ឌនៃមុខងារជាអាណត្តិទូទៅរបស់ខ្លួន ដោយផ្អែកលើតម្រូវការរបស់ប្រជាពលរដ្ឋ និងអាទិភាពនានាដែលបានកំណត់ក្នុងដំណើរការរៀបចំផែនការដោយមានការចូលរួមពីប្រជាពលរដ្ឋ។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនឹងក្លាយទៅតួអង្គកាន់តែសំខាន់ក្នុងការអនុម័តផែនការ គម្រោងថវិកា និងលិខិតបទដ្ឋានគតិយុត្ត និងការត្រួតពិនិត្យមើលលើការគ្រប់គ្រងផ្នែករដ្ឋបាលសំដៅធានាបានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រចនាសម្ព័ន្ធនៃគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សានឹងត្រូវកែសម្រួល ដើម្បីជួយក្រុមប្រឹក្សាក្នុងការអនុវត្តតួនាទីទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព។

រដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់ថ្នាក់ទាំងអស់នឹងត្រូវរៀបចំ និងអនុវត្តផែនការជាយុទ្ធសាស្ត្រក្នុងការបញ្ជ្រាបបញ្ហាអន្តរវិស័យនានារួមមាន ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការត្រៀមផ្តល់អន្តរាគមន៍ពេលមានគ្រោះមហន្តរាយ ជំងឺរាតត្បាត លើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។

ការរៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើចក្ខុវិស័យទាំងនេះ នឹងតម្រូវឱ្យមានការពិនិត្យឡើងវិញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងអាចកែសម្រួលបន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។

រដ្ឋបាលថ្នាក់ជាតិនឹងរក្សាទុកនូវមុខងារសំខាន់ៗពាក់ព័ន្ធនឹងការងារសន្តិសុខជាតិ ការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណត់ទិសដៅជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជាតិ ក៏ដូចជាការគ្រប់គ្រង

ដោយផ្ទាល់លើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់សេវាសាធារណៈ និងកម្មវិធីវិនិយោគសាធារណៈ ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ។ ក្នុងការធ្វើវិមជ្ឈការមុខងារ រដ្ឋបាលថ្នាក់ជាតិនឹងរក្សាទុកនូវសិទ្ធិអំណាចពេញលេញសម្រាប់ការធានានូវសង្គតិភាពនៃការគ្រប់គ្រង និងការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្របខ័ណ្ឌគោលនយោបាយជាតិ ការធានាលើការប្រើប្រាស់ធនធានថវិកាប្រកបដោយប្រសិទ្ធភាព ការកំណត់បទដ្ឋានសម្រាប់ការផ្តល់សេវា ការសម្របសម្រួល ការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមុខងារអធិការកិច្ច និងការត្រួតពិនិត្យនីត្យានុកូលភាព។ ក្របខ័ណ្ឌសម្រាប់អនុវត្តសិទ្ធិ អំណាចទាំងនេះនឹងត្រូវបានរៀបចំ និងកំណត់បន្ថែមទៀតនៅក្នុងកម្មវិធីជាតិដំណាក់កាលទី២។

ប្រទេសកម្ពុជាជារដ្ឋទោលមួយដែលសិទ្ធិ អំណាច និងមុខងារទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រគល់ ឬធ្វើប្រតិភូកម្មដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត អាស្រ័យហេតុនេះ ក្នុងករណីចាំបាច់ សិទ្ធិ អំណាច និងមុខងារទាំងនេះក៏អាចដកត្រឡប់មកវិញបានផងដែរ។

## ២. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នឹងមានបុគ្គលិកគ្រប់គ្រាន់ ហើយបុគ្គលិកទាំងនោះមានលក្ខណៈសម្បត្តិសមស្របទាំងសមត្ថភាពជំនាញ និងបទពិសោធន៍ការងារ។ បុគ្គលិកម្នាក់ៗនឹងត្រូវមានលក្ខខណ្ឌការងារប្រចាំឆ្នាំច្បាស់លាស់ដោយផ្អែកលើការពិពណ៌នាមុខតំណែងនីមួយៗ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គភាព។ លទ្ធផលនៃការបំពេញការងាររបស់បុគ្គលិកទាំងនោះនឹងត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់។ បុគ្គលិកទាំងអស់នឹងត្រូវបានរៀបចំឱ្យមានការគ្រប់គ្រងតាមឋានានុក្រមយ៉ាងត្រឹមត្រូវ។ សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់អ្នកគ្រប់គ្រងនៅតាមកម្រិតឋានានុក្រមនីមួយៗនឹងត្រូវកំណត់ឱ្យមានភាពច្បាស់លាស់ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រង និងចាត់ចែងការងារប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនឹងប្រតិបត្តិការងារប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងមានឆន្ទៈម្ចាស់ការចំពោះការបំពេញតួនាទីរបស់ខ្លួន ហើយត្រូវទទួលបានប្រាក់បៀវត្ស ប្រាក់លើកទឹកចិត្តសមរម្យ និងទទួលបាននូវការដំឡើងឋានន្តរស័ក្តិ ថ្នាក់ជាដើម។ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងឈានមុខក្នុងការជ្រើសរើសបុគ្គលិក និងការតែងតាំងមុខតំណែងគ្រប់គ្រងដោយផ្តល់អាទិភាពជាសំខាន់ទៅលើស្ត្រី និងក្រុមជនងាយរងគ្រោះ។

រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានការទទួលខុសត្រូវពេញលេញក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួនដោយផ្អែកតាមគោលការណ៍ បែបបទ នីតិវិធីនៃលក្ខន្តិកៈដោយឡែក និងលិខិតបទដ្ឋានគតិយុត្តសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្អែកតាមលក្ខខណ្ឌដែលបានកំណត់តាមអង្គវិជ្ជាជីវៈនីមួយៗនៃមន្ត្រីរាជការស៊ីវិល។

នៅឆ្នាំ២០៣០ ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពដ៏មានប្រសិទ្ធភាពមួយសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដោយ

នឹងផ្តោតជាសំខាន់លើការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងជំនាញបច្ចេកទេសនៃបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមការពិពណ៌នាមុខតំណែង និងជំនាញវិជ្ជាជីវៈរបស់បុគ្គលិកម្នាក់ៗ។ ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពនេះ ត្រូវឆ្លើយតបទៅនឹងតម្រូវការនៃការបណ្តុះបណ្តាលដែលកំណត់ដោយស្ថាប័នថ្នាក់ជាតិ និងតម្រូវការនៃការបណ្តុះបណ្តាលដែលកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផែនការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់បុគ្គលិកម្នាក់ៗ។

ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពនេះនឹងកំណត់ឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវក្នុងការរៀបចំការបណ្តុះបណ្តាល ការផ្តល់សេវាបណ្តុះបណ្តាល និងការរៀបចំខ្លឹមសារសម្រាប់ការបណ្តុះបណ្តាល។ ការបណ្តុះបណ្តាលនឹងត្រូវបានផ្តល់ដោយស្ថាប័នជំនាញនានានៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដោយមានសាលាជាតិរដ្ឋបាលមូលដ្ឋានមានតួនាទីស្នូលក្នុងការអភិវឌ្ឍស្តង់ដាសម្រាប់បណ្តុះបណ្តាល ការរៀបចំសម្ភារៈបណ្តុះបណ្តាល ការបណ្តុះបណ្តាលគ្រូបង្គោល ព្រមទាំងផ្តល់ការបណ្តុះបណ្តាលដោយផ្ទាល់មួយចំនួនផងដែរ។ កម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនឹងត្រូវរៀបចំ និងបណ្តុះបណ្តាលដល់បុគ្គលិកទៅតាមមុខជំនាញវិជ្ជាជីវៈផ្សេងៗគ្នា។

ផ្នែកដ៏សំខាន់មួយទៀតនៃការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺការរៀនតាមប្រព័ន្ធអេឡិចត្រូនិកដែលគាំទ្រដោយគ្រូជំនាញឯកទេសនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន ឬនៅតាមស្ថាប័នផ្សេងទៀត និងតាមរយៈវគ្គសិក្សានៅនឹងកន្លែងរយៈពេលខ្លី និងរយៈពេលវែង។

### ៣. ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នឹងទទួលបានធនធានហិរញ្ញវត្ថុពីប្រភពនានាដែលមានទំហំសមស្របទៅនឹងកាតព្វកិច្ចចំណាយរបស់ខ្លួនទាំងបរិមាណ និងប្រភេទចំណាយ។

ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានចំណូលពីការផ្ទេរពីថ្នាក់ជាតិក្នុងបែបផែនជាការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ និងធនធានហិរញ្ញវត្ថុគ្មានភ្ជាប់លក្ខខណ្ឌដែលត្រូវកំណត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនិងរូបមន្តសមស្របនិងច្បាស់លាស់ ចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបានពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធនៅតាមមូលដ្ឋានរបស់ខ្លួន ព្រមទាំងចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត។

ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌនឹងត្រូវបានផ្ទេរក្នុងទំហំសមស្របទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ធនធានហិរញ្ញវត្ថុផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌនឹងត្រូវបង្កើន ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពសមស្របក្នុងការរ៉ាប់រងលើការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើសដែលរួមបញ្ចូលទាំងមុខងារដែលមានលក្ខណៈពហុវិស័យនានា ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការកាន់តែច្រើនឡើងៗរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធនៅតាមមូលដ្ឋាននានានឹងត្រូវបានបង្កើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការគិតគូរពិចារណាអំពីការប្រគល់បន្ថែមនូវប្រភេទពន្ធ និងការ

បង្កើនអត្រាចែករំលែកចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ សំដៅពង្រឹងគណនេយ្យភាព និងការទទួលខុសត្រូវក្នុងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើការផ្ទេរថវិកាពីរដ្ឋបាលថ្នាក់ជាតិ។ ការបែងចែកធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពីប្រភពខាងលើនេះនឹងត្រូវធានាឱ្យបាននូវគោលការណ៍សមធម៌។

ក្រៅពីប្រភពធនធានខាងលើ រាជរដ្ឋាភិបាលនឹងបង្កើតនូវយន្តការផ្តល់ហិរញ្ញប្បទានបន្ថែម ក្នុងគោលបំណងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ និងជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាប៉ូលសេដ្ឋកិច្ចសំខាន់របស់ជាតិដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ។

នៅឆ្នាំ២០៣០ ត្រូវបានរំពឹងថាធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងមួយចំនួននឹងទទួលបានធនធានហិរញ្ញវត្ថុជាចម្បងពីប្រភពចំណូលនៅមូលដ្ឋាន។ ដោយឡែក រដ្ឋបាលស្រុក និងរដ្ឋបាលឃុំនឹងទទួលបានធនធានហិរញ្ញវត្ថុជាចម្បងពីប្រភពដែលបែងចែកពីថ្នាក់ជាតិ។

រាជរដ្ឋាភិបាលនឹងធ្វើការសិក្សាក្នុងការបង្កើតក្របខ័ណ្ឌការងារមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ដោយផ្អែកទៅលើកាតព្វកិច្ច និងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងគម្រោងនានា។

### ៤. ការរៀបចំផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិនឹងបន្ត និងពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ផ.យ.ថ.) ដោយផ្អែកលើកម្មវិធីវិនិយោគ៣(បី)ឆ្នាំរំកិល និងផែនការអភិវឌ្ឍន៍រយៈពេល៥(ប្រាំ)ឆ្នាំរបស់ខ្លួន។ ផ.យ.ថ.នេះនឹងធានានូវការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានានៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផង និងតម្រង់ទិសឱ្យការប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានសង្គតិភាពជាមួយនឹងអាទិភាពគោលនយោបាយជាតិផងដែរ។

នៅឆ្នាំ២០៣០ រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកនឹងត្រូវអនុវត្តតាមប្រព័ន្ធថវិកាកម្មវិធី ដើម្បីធានាដល់ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយជាតិផងដែរ។ ក្នុងការអនុវត្តប្រព័ន្ធថវិកាកម្មវិធីនេះនឹងត្រូវពង្រីកជាបណ្តើរៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដោយផ្អែកលើសមត្ថភាព និងភាពចាំបាច់។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតនឹងបំពេញតួនាទីកាន់តែល្អប្រសើរជាងមុនក្នុងការត្រួតពិនិត្យលើកិច្ចដំណើរការរៀបចំ និងអនុវត្តថវិកានៃរដ្ឋបាលរបស់ខ្លួន។ ក្នុងនាមជាតំណាងឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សានឹងមានតួនាទីសំខាន់ក្នុងការធានាថា ផែនការចំណាយត្រូវឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពនានារបស់មូលដ្ឋានក្នុងក្របខ័ណ្ឌនៃឆន្ទានុសិទ្ធិដែលបានកំណត់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ យន្តការជាក់លាក់មួយដែលដឹកនាំដោយក្រុមប្រឹក្សានឹងត្រូវពិនិត្យ និងបង្កើត ដើម្បីធានាការអនុវត្តតួនាទីទាំងនេះប្រកបដោយប្រសិទ្ធភាព។

សមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ កិច្ចលទ្ធកម្ម និងការងារពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋបាល

ថ្នាក់ក្រោមជាតិនឹងត្រូវបានបង្កើន តាមរយៈការបណ្តុះបណ្តាលដែលមានលក្ខណៈជាប្រព័ន្ធ ហើយការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈនឹងត្រូវបានរៀបចំឡើងសម្រាប់បុគ្គលិកដែលមានតួនាទី និងការទទួលខុសត្រូវពាក់ព័ន្ធនឹងការងារទាំងនេះ។

កិច្ចការខាងលើនេះនឹងត្រូវរៀបចំ និងអនុវត្តដោយផ្អែកលើយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនេះនឹងធានាថា ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈសាមញ្ញ ងាយស្រួលអាចបត់បែនបាន មានគណនេយ្យភាព តម្លាភាព ក្នុងគោលដៅផ្តល់ឆន្ទានុសិទ្ធិកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗក្នុងការរៀបចំ និងអនុវត្តថវិការបស់ខ្លួន។

ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងឯកសារយុទ្ធសាស្ត្រពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវមានការពិនិត្យ និងកែសម្រួលឱ្យស្របទៅនឹងគោលការណ៍នៃកំណែទម្រង់វិមជ្ឈការ។

### ៥. រដ្ឋបាលអេឡិចត្រូនិច (E-Government)

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវដាក់ឱ្យអនុវត្តនូវបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងកិច្ចការចាំបាច់មួយចំនួនរបស់ខ្លួន និងអាចឈានទៅអនុវត្តនៅគ្រប់កិច្ចការទាំងអស់ផ្អែកតាមសមត្ថភាព និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងផ្អែកតាមភាពរីកចម្រើននៃប្រព័ន្ធព័ត៌មានវិទ្យា និងការយល់ដឹងរបស់ប្រជាពលរដ្ឋ ស្របទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនូវបច្ចេកវិទ្យាព័ត៌មានវិទ្យានៅក្នុងប្រទេសកម្ពុជា ព្រមទាំងស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់ឧស្សាហកម្ម៤.០ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសអភិវឌ្ឍន៍។

កិច្ចការចាំបាច់នានាដែលនឹងអាចគ្រប់គ្រង និងផ្តល់សេវាតាមប្រព័ន្ធព័ត៌មានវិទ្យារួមមានដូចជា ទំនាក់ទំនងការរវាងរដ្ឋបាលនិងរដ្ឋបាល ទំនាក់ទងការងាររវាងរដ្ឋបាលនិងប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធផ្សេងៗទៀត ការផ្តល់សេវាធារណៈ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍសមត្ថភាពជាដើម។

ការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិចមានទិដ្ឋភាពច្រើនយ៉ាង ប៉ុន្តែត្រូវផ្តោតលើការយល់ដឹងផ្នែកបច្ចេកទេសព័ត៌មានវិទ្យា និងការបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវរៀនសូត្រមិនត្រឹមតែអំពីរបៀប និងដំណើរការកម្មវិធីឌីជីថលប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៀតនោះគឺការច្នៃប្រឌិតបញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងការងាររបស់ខ្លួន។

### ៦. ការទទួលបានព័ត៌មាន តម្លាភាព និងគណនេយ្យភាព

នៅឆ្នាំ២០៣០ ប្រជាពលរដ្ឋនឹងមានការយល់ដឹងទូលំទូលាយ និងទទួលបានព័ត៌មានច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីសេវាសាធារណៈដែលអាចទទួលបាន អំពីស្តង់ដានៃការផ្តល់សេវាសាធារណៈ អំពីផែនការសកម្មភាពនិងធនធាននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អំពីរបៀបនៃការប្រាស្រ័យទាក់ទង

ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមផ្តល់មតិយោបល់ ចូលរួមអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ក្រៅពីនេះ ប្រជាពលរដ្ឋនឹងយល់ដឹងអំពីទីកន្លែង និងរបៀបនៃការដាក់ពាក្យបណ្តឹងតវ៉ានានា។

ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងបំពេញតួនាទីរបស់ខ្លួនជាតំណាងជាប់ឆ្នោតរបស់ប្រជាពលរដ្ឋតាមរយៈការធ្វើសេចក្តីសម្រេចចិត្ត និងការត្រួតពិនិត្យលើការអនុវត្តការងាររបស់គណៈអភិបាល និងបុគ្គលិករបស់ខ្លួនកាន់តែមានប្រសិទ្ធភាព ព្រមទាំងតាមរយៈការរៀបចំយន្តការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋប្រកបដោយភាពទំនើប ងាយស្រួល បើកចំហ តម្លាភាព និងបរិយាប័ន្ន។

នៅឆ្នាំ២០៣០ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងកាន់តែមានភាពជាម្ចាស់លើការងារគណនេយ្យភាព និងជំរុញការអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីធានានិរន្តរភាព និងប្រសិទ្ធភាពនៃការអនុវត្តការងារគណនេយ្យភាពនេះ។ ការងារគណនេយ្យភាពនឹងត្រូវបានពង្រឹង តាមរយៈការបន្តអនុវត្តការងារគណនេយ្យភាពសង្គម ការិយាល័យប្រជាពលរដ្ឋ និងយន្តការផ្សេងទៀត។ អង្គការសង្គមស៊ីវិលនឹងបន្តបំពេញតួនាទីសំខាន់របស់ខ្លួនក្នុងភាពជាដៃគូជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសនៅក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ព្រមទាំងតាមរយៈការសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការកសាងផែនការ ថវិកា ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់ព័ត៌មានត្រឡប់ទៅឱ្យអង្គភាពផ្តល់សេវា។

ប្រភេទឯកសារនានាដែលត្រូវផ្សព្វផ្សាយជាសាធារណៈជូនប្រជាពលរដ្ឋ រួមមានដូចជាផែនការ ថវិកា របាយការណ៍ស្តីពីសមិទ្ធផលរូបវន្តនានា និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវមានការណែនាំច្បាស់លាស់មួយ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិមានកាតព្វកិច្ចក្នុងការផ្សព្វផ្សាយនូវព័ត៌មានទាំងនេះ។

រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមិនត្រឹមតែផ្សព្វផ្សាយព័ត៌មាននានាដែលជាកាតព្វកិច្ចរបស់ខ្លួននោះឡើយ ប៉ុន្តែថែមទាំងនឹងរៀបចំ និងដាក់ឱ្យអនុវត្តនូវវិធីសាស្ត្រសម្រាប់ការប្រាស្រ័យទាក់ទងកាន់តែសកម្មជាមួយពលរដ្ឋអំពីបញ្ហាសំខាន់ៗ ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងតាមបែបទំនើប ដើម្បីធានាថាគ្រប់ក្រុមប្រជាជនទទួលបាននូវព័ត៌មានទាំងនេះ។

## IV. គោលបំណង និងគោលដៅនៃកម្មវិធីជាតិ

### ១. គោលបំណង

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២មានគោលបំណង *លើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ បរិយាប័ន្ន សមធម៌ និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការកែលំអនូវដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកក្នុងការលុបបំបាត់ភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង។*

គោលបំណងខាងលើនេះបានឆ្លុះបញ្ចាំង និងធ្វើបច្ចុប្បន្នភាពនូវគោលបំណងនៃកម្មវិធីជាតិដំណាក់កាលទី១ និងការដាក់បញ្ចូលនូវគោលដៅជាយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលដែលបានកំណត់ថា ប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិត្រូវធ្វើទំនើបកម្ម ស្របតាមការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៅក្នុងសង្គមកម្ពុជា និងសេចក្តីត្រូវការរបស់ប្រទេសជាតិនាពេលអនាគត នៅពេលដែលសេដ្ឋកិច្ចជាតិរីកចម្រើនក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់។

**២. គោលដៅ**

គោលដៅនៃកម្មវិធីជាតិដំណាក់កាលទី២ នៅឆ្នាំ២០៣០គឺ *រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារទាំងឡាយក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។*

## V. យុទ្ធសាស្ត្រកម្មវិធីជាតិ

មូលដ្ឋានគ្រឹះដ៏សំខាន់នៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ គឺការគាំទ្រពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលទៅលើចក្ខុវិស័យ គោលបំណង គោលដៅ និងសមាសភាគនានានៃកម្មវិធីជាតិដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ន អ្នកពាក់ព័ន្ធនានា ព្រមទាំងប្រជាពលរដ្ឋ។

ផ្អែកលើការស្រុះស្រួលមតិគ្នាយ៉ាងទូលំទូលាយលើចក្ខុវិស័យ គោលបំណង និងគោលដៅនៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិនេះ កម្មវិធីជាតិដំណាក់កាលទី២នឹងកំណត់អំពីលទ្ធផលរំពឹងទុកជាក់លាក់ និងអាចសម្រេចបានសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង និងត្រូវរៀបចំផែនការសកម្មភាពលម្អិត ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុកទាំងនោះ។

កម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវបែងចែកជា "**សមាសភាគ**" ដែលសមាសភាគទាំងនេះត្រូវមានទំនាក់ទំនងគ្នា និងត្រូវអនុវត្តដោយមានកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធ។ ការកំណត់សមាសភាគទាំងនេះនឹងត្រូវរៀបចំឱ្យមានលក្ខណៈសមស្របជាមួយនឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នដឹកនាំអនុវត្តសមាសភាគនីមួយៗ។

កម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវអនុវត្តជាដំណាក់កាលៗ តាមរយៈផែនការអនុវត្តពហុឆ្នាំ។ តាមការរំពឹងទុក កម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវរៀបចំជាពីរដំណាក់កាល ដែលដំណាក់កាលនីមួយៗមានរយៈពេល០៥ឆ្នាំ។

ឯកសារកម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវកំណត់នូវលទ្ធផលចម្បងៗសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃនៅក្នុងរយៈពេលនៃកម្មវិធីជាតិទាំងមូល។ ក្របខ័ណ្ឌលទ្ធផលនៃកម្មវិធីជាតិនឹងត្រូវរៀបចំ ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់។ ផែនការអនុវត្តដំណាក់កាលនីមួយៗនឹងត្រូវរៀបចំឱ្យ

ស្របជាមួយក្របខ័ណ្ឌលទ្ធផលនេះ។ ចំពោះផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនឹងត្រូវរៀបចំផ្អែកលើផែនការអនុវត្តដំណាក់កាលនីមួយៗ។

ការរៀបចំបែបផែននៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ អាចមានការប្រែប្រួលក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិទាំងមូល។ ដូច្នេះ គោលការណ៍សម្រាប់ការអនុវត្ត និងការណែនាំតម្រង់ទិសសម្រាប់ការរៀបចំផែនការអនុវត្តដំណាក់កាលដំបូងនឹងត្រូវកំណត់នៅក្នុងឯកសារកម្មវិធីជាតិដំណាក់កាលទី២។ បែបផែននៃការអនុវត្តលម្អិតដែលរួមបញ្ចូលនូវការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ នឹងត្រូវកំណត់នៅក្នុងផែនការអនុវត្តដំណាក់កាលនីមួយៗ។

កម្មវិធីជាតិដំណាក់កាលទី២គឺជារបៀបវារៈមួយនៃការធ្វើទំនើបភាវូបនីយកម្ម និងកំណែទម្រង់វិស័យសាធារណៈដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាល។ ភាពជោគជ័យនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២នេះ មានភាពពាក់ព័ន្ធទៅនឹងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ អាស្រ័យហេតុនេះ កម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវរៀបចំតាក់តែងដើម្បីធានាដល់ការសម្របសម្រួល និងកិច្ចសហការជាមួយកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

## VI. សមាសភាគកម្មវិធី និងការងារអន្តរវិស័យ

### ក. សមាសភាគកម្មវិធី

កម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវបានរៀបចំជាសមាសភាគចំនួន៥ ដូចខាងក្រោម៖

**១. ការដឹកនាំ និងការគ្រប់គ្រងការងារកំណែទម្រង់**

**២. រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**

**៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

**៤. វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការថ្នាក់ក្រោមជាតិ**

**៥. ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។**

សមាសភាគនីមួយៗនឹងត្រូវកំណត់ឱ្យមានសមិទ្ធផលរំពឹងទុកជាចម្បងមួយ និងកិច្ចការជាអាទិភាពនានាដែលត្រូវសម្រេចឱ្យបានក្នុងកម្មវិធីជាតិដំណាក់កាលទី២នេះ។

#### ១. ការដឹកនាំ និងការគ្រប់គ្រងការងារកំណែទម្រង់

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានភាពជាម្ចាស់ និងការទទួលខុសត្រូវពេញលេញក្នុងការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។*

កិច្ចការជាអាទិភាពនានានៃសមាសភាគនេះរួមមាន៖

- ការបន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ គ.ជ.អ.ប. ក្នុងការដឹកនាំ ការសម្របសម្រួល ការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីជាតិ ផែនការអនុវត្តតាមដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ។

- ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប. ដើម្បីសិក្សាស្រាវជ្រាវ និងផ្តល់យោបល់ជូន គ.ជ.អ.ប. លើកិច្ចការនានាពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន។

- ការពិនិត្យ ការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ច និងការពង្រឹងសមត្ថភាពរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីធ្វើជាសេនាធិការជូន គ.ជ.អ.ប. និងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. និងផ្តល់ការសម្របសម្រួល គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ព្រមទាំងបំពេញតួនាទីជាភ្នាក់ងារសម្របសម្រួល និងអនុវត្តកម្មវិធី និងគម្រោងនានាក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

- ការពង្រឹងយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ដើម្បីធានាដល់ការលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវពេញលេញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រកបដោយប្រសិទ្ធភាព។

- ការពិនិត្យមើលឡើងវិញ និងការបែងចែកឱ្យបានច្បាស់លាស់នូវមុខងារ និងការទទួលខុសត្រូវរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គភាពពាក់ព័ន្ធនានានៃក្រសួងមហាផ្ទៃក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេស ការគាំទ្រការអភិវឌ្ឍសមត្ថភាព ការគាំទ្របច្ចេកទេស ការតាមដានត្រួតពិនិត្យ និងវាយតម្លៃដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- ការបន្តពង្រឹងកិច្ចសហការជាមួយកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកំណែទម្រង់តាមវិស័យនានា ដើម្បីធានានូវភាពប្រទាក់ក្រឡានិងស៊ីសង្វាក់គ្នា ព្រមទាំងបំពេញឱ្យគ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព។

- ការពង្រឹង និងការគាំទ្រដល់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាតំណាងឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសសម្រាប់ផ្តល់ការគាំទ្រ ការការពារ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- ការសម្របសម្រួល និងការពង្រឹងកិច្ចសហការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនក្នុងការគៀរគរការគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និង

វិសហមជ្ឈការ។

– ការបន្តពង្រឹងការផ្សព្វផ្សាយព័ត៌មាន និងការបង្កើនការយល់ដឹងដល់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសាធារណជនអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**២. រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់ តាមថ្នាក់ និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈនៃរដ្ឋបាលទីក្រុងធំ ទីប្រជុំជន និងទីជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ។*

កិច្ចការជាអាទិភាពនានានៃសមាសភាគនេះ រួមមាន៖

– ការរៀបចំកែសម្រួល និងពង្រឹងរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងការធ្វើវិចារណកម្មមុខងាររបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់។ ការរៀបចំរដ្ឋបាលរាជធានីទៅជារដ្ឋបាលម៉េត្រូប៉ូលីតែន (Metropolitan) និងការរៀបចំរដ្ឋបាលខេត្តទៅជារដ្ឋបាលតំបន់ស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ។ រដ្ឋបាលទីប្រជុំជន(ខណ្ឌ/សង្កាត់ និងក្រុង/សង្កាត់) និងរដ្ឋបាលជនបទ(ស្រុក/ឃុំ)នឹងត្រូវបានបែងចែកឱ្យមានភាពខុសគ្នាក្នុងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងគ្នារវាងរដ្ឋបាលក្រុងជាមួយរដ្ឋបាលសង្កាត់ រដ្ឋបាលខណ្ឌជាមួយរដ្ឋបាលសង្កាត់ និងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ។ ក្របខ័ណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតនឹងត្រូវបានបង្កើតឡើង។

– ការបន្តផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើគោលការណ៍ប្រសិទ្ធភាព គណនេយ្យភាព និងភាពសមស្របទៅនឹងថ្នាក់ ឬប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ភាពខុសគ្នារវាងមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសនឹងត្រូវបានកំណត់ឱ្យកាន់តែមានភាពច្បាស់លាស់ថែមទៀត។

– ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ តាមរយៈការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ការផ្តល់សេវាសាធារណៈ និងការប្រាស្រ័យទាក់ទងសាធារណៈ។

– ការបង្កើតប្រព័ន្ធអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈឯកភាពមួយ ដើម្បីត្រួតពិនិត្យនីត្យានុកូលភាពទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយធានានូវស្វ័យភាព និងការផ្តួចផ្តើមគំនិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

– ការពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជាការទទួលខុសត្រូវក្នុងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ ការរៀបចំនិងការអនុម័តថវិកា ការត្រួត

ពិនិត្យលើការអនុវត្តថវិកា ការរៀបចំដីកាឬលិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម។

– ការពិនិត្យ និងការកែសម្រួលគណៈកម្មាធិការនានា និងនីតិវិធីអនុវត្តការងាររបស់ក្រុមប្រឹក្សា ព្រមទាំងការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួន និងមានចំនួនបុគ្គលិកគ្រប់គ្រាន់ប្រកបដោយឆន្ទៈម្ចាស់ការ មានសមត្ថភាព និងជំនាញវិជ្ជាជីវៈស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបាននូវការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈជាប្រចាំ។*

សមាសភាគនេះនឹងបង្កើត្នាយ៉ាងជិតស្និទ្ធជាមួយកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈដោយផ្តោតជាសំខាន់ទៅលើការងារធំៗចំនួន២ រួមមាន៖

**៣.១. ការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលរួមមានកិច្ចការជាអាទិភាពមួយចំនួនដូចខាងក្រោម៖

– ការរៀបចំប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមបច្ចេកវិទ្យាព័ត៌មានវិទ្យានៅថ្នាក់ក្រោមជាតិ ដោយមានលក្ខណៈផ្សារភ្ជាប់គ្នាជាប្រព័ន្ធជាមួយប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យានៅថ្នាក់ជាតិ។

– ការរៀបចំ និងដាក់ឱ្យអនុវត្តនូវអង្គមន្ត្រីរាជការស៊ីវិល ដើម្បីធានាដល់ការជ្រើសរើស ការគ្រប់គ្រង និងការរៀបចំបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមកម្រិតនៃការបណ្តុះបណ្តាល និងជំនាញវិជ្ជាជីវៈ។

– ការវាយតម្លៃ និងកំណត់អំពីតម្រូវការធនធានមនុស្សដែលរួមមានដូចជា ចំនួនបុគ្គលិក និងជំនាញវិជ្ជាជីវៈរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកំណត់អំពីតម្រូវការជំនាញវិជ្ជាជីវៈនេះគឺដើម្បីជាមូលដ្ឋានក្នុងការបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិកដែលមានស្រាប់ និងដើម្បីជ្រើសរើសបុគ្គលិកឱ្យបានសមស្របទៅនឹងតម្រូវជំនាញវិជ្ជាជីវៈទាំងនោះ។

– ការរៀបចំនីតិវិធីសម្រាប់ជ្រើសរើស និងគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំឱ្យមានក្រមសីលធម៌សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការរៀបចំការពិពណ៌នាមុខតំណែងគ្រប់គ្រង និងមុខតំណែងវិជ្ជាជីវៈសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលនូវលក្ខខណ្ឌការងារ និងការរៀបចំក្របខ័ណ្ឌនិងកំណត់សូចនាករសម្រាប់វាយតម្លៃការ

បំពេញការងាររបស់បុគ្គលិកតាមមុខតំណែងនីមួយៗ។

– ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការវាយតម្លៃអំពីតម្រូវការនៃការរៀបចំបុគ្គលិក និងតម្រូវការនៃការអភិវឌ្ឍសមត្ថភាពបុគ្គលិក រួមទាំងការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងការកំណត់ស្ថាប័នផ្តល់សេវាអភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣.២. ការកសាងសមត្ថភាពជំនាញទូទៅ និងជំនាញវិជ្ជាជីវៈដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលរួមមានកិច្ចការជាអាទិភាពមួយចំនួនដូចខាងក្រោម៖

– ការពង្រឹងការរៀបចំស្ថាប័នបណ្តុះបណ្តាលថ្នាក់ជាតិ(សាលាជាតិរដ្ឋបាលមូលដ្ឋាន) និងការរៀបចំបង្កើតស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ ព្រមទាំងកសាងសមត្ថភាពស្ថាប័នបណ្តុះបណ្តាលទាំងនេះ ដើម្បីផ្តល់ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការបង្កើតកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលជំនាញរដ្ឋបាល និងជំនាញទូទៅដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការបង្កើត "កម្មវិធីបណ្តុះបណ្តាល" ដើម្បីរៀបចំការបណ្តុះបណ្តាលដោយផ្អែកលើតម្រូវការអភិវឌ្ឍន៍សមត្ថភាពដែលបានកំណត់ក្នុងសមាសភាគនីមួយៗ។

– ការបង្កើតវិធីសាស្ត្របណ្តុះបណ្តាលជាក់លាក់មួយចំនួន ដូចជាការបណ្តុះបណ្តាលលើប្រធានបទជាក់លាក់ណាមួយឬច្រើន ឬការរៀនតាមអនឡាញ(On-Line) និងការសិក្សាដោយខ្លួនឯង។

– ការបង្កើតក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈពេញមួយអាជីពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិរួមបញ្ចូលនូវសិទ្ធិទទួលបានការបណ្តុះបណ្តាល និងកាតព្វកិច្ចរបស់បុគ្គលិកក្នុងការបង្កើនកម្រិតជំនាញវិជ្ជាជីវៈរបស់ខ្លួន ដោយផ្សារភ្ជាប់ទៅនឹងការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងមុខតំណែងដល់បុគ្គលិកទាំងនោះ។

វិធីសាស្ត្រសម្រាប់ការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈនេះនឹងត្រូវរៀបចំឡើងដោយផ្តល់ឱកាសបន្ថែមដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀនសូត្រពីគ្នាទៅវិញទៅមក តាមរយៈការធ្វើទស្សនកិច្ចសិក្សា និងការបង្កើតបណ្តាញគាំទ្រដល់ការពង្រឹងវិជ្ជាជីវៈ និងការរៀនសូត្រនានាសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤. ទិសដៅការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការថ្នាក់ក្រោមជាតិ

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានធនធានថវិកាសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជន៍សម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបនឹងតម្រូវការនានាដូចមានកំណត់ក្នុងផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

សមាសភាគនេះនឹងត្រូវផ្សារភ្ជាប់ជាមួយសមាសភាគរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសមាសភាគផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីកំណត់សូចនាករសមិទ្ធកម្មសម្រាប់ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើកិច្ចការជាអាទិភាពនានា រួមមាន៖

– ការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំជាមួយនឹងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការកំណត់ និងការបែងចែកចំណូលថវិកា (ចំណូលផ្ទេរពីថ្នាក់ជាតិ និងចំណូលនៅមូលដ្ឋាន) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងទំហំសមស្របទៅនឹងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានមុខងារជាកាតព្វកិច្ចដែលបានផ្ទេរ មុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រូបមន្តបែងចែកចំណូលថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ដើម្បីជាមូលដ្ឋានអាចធ្វើការព្យាករណ៍បានដោយមានភាពប្រាកដប្រជា។

– ការបង្កើតមូលនិធិភាតរភាព (ការចែករំលែកធនធានពីរដ្ឋបាលដែលមានចំណូលខ្ពស់មកជួយរដ្ឋបាលដែលមានចំណូលទាប) ក្នុងគោលបំណងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ និងការបង្កើតមូលនិធិពិសេសនានា ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាប៉ូលសេដ្ឋកិច្ចសំខាន់របស់ជាតិ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ។

– ការពិនិត្យ និងការកែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ប្រសិទ្ធភាព ស្វ័យភាព តម្លាភាព និងគណនេយ្យភាព និងស្របទៅតាមប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

– ការពង្រឹងការអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពកម្រិតគោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងថវិការដ្ឋ។

– ការបង្កើនការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងលើការអនុវត្តថវិកា និងកិច្ចលទ្ធកម្ម ព្រមទាំងការពង្រឹងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន និងផ្តល់ការគាំទ្រដល់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលចំណូលសារពើពន្ធឱ្យកាន់តែមានប្រសិទ្ធភាព។

– ការពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាក្នុងការពិនិត្យ និងអនុម័តគម្រោងថវិកា ដើម្បីធានាឱ្យមានសង្គតិភាពជាមួយនឹងគោលការណ៍ណែនាំនានាដែលបានកំណត់ និងធានាឱ្យមានធនធានហិរញ្ញវត្ថុសមស្របសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ច ព្រមទាំងការពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាក្នុងការត្រួតពិនិត្យលើការអនុវត្តថវិកា។

– ការរៀបចំស្តង់ដា និងនីតិវិធីសម្រាប់ការធ្វើសវនកម្មលើការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការពិនិត្យ និងការកែសម្រួលច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របទៅនឹងគោលការណ៍នៃកំណែទម្រង់វិមជ្ឈការ។

## ៥. ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

សមិទ្ធផលរំពឹងទុកនៃសមាសភាគនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាអាណត្តិទូទៅ ឬមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងសម្រុះ សម្រួលដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។*

កិច្ចការជាអាទិភាពនៃសមាសភាគនេះ រួមមានៈ

– ការរៀបចំ ការកែសម្រួល និងការពង្រឹងយន្តការ នីតិវិធី និងស្តង់ដានៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដោយមានការកំណត់នូវសូចនាករសមិទ្ធកម្មសំខាន់ៗសម្រាប់ដាក់ឱ្យអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការកំណត់ឱ្យបានច្បាស់លាស់នូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសឬមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានក្នុងការបែងចែក និងការប្រើប្រាស់ធនធាននានាសម្រាប់ការអនុវត្តមុខងារទាំងនោះស្របតាមលក្ខខណ្ឌដែលបានកំណត់ និងឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងចងក្រងនូវមេរៀន និងបទពិសោធន៍ល្អៗអំពីការអនុវត្តមុខងារទាំងនេះសម្រាប់ការចែករំលែកគ្នាទៅវិញទៅមកក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការរៀបចំនូវក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងរដ្ឋបាលថ្នាក់ជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

– ការរៀបចំកែសម្រួល និងការពង្រឹងការអនុវត្តយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋប្រកបដោយលក្ខណៈសាមញ្ញ ឆាប់រហ័ស តម្លាភាព គណនេយ្យភាព និងភាពងាយស្រួលក្នុងការទទួលបានសេវា ដោយជំរុញការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា។

– ការពង្រឹង និងការពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គម ដោយជំរុញការរៀបចំអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការប្រាស្រ័យទាក់ទង និងការចូលរួមពិនិត្យ តាមដាន វាយតម្លៃ និងផ្តល់យោបល់របស់ប្រជាពលរដ្ឋលើការផ្តល់សេវាសាធារណៈ និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការពង្រឹងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មាន និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ។

– ការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋ និងយន្តការសម្រុះសម្រួលវិវាទមូលដ្ឋាននៅថ្នាក់ក្រោមជាតិ ដើម្បីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋក្រៅប្រព័ន្ធតុលាការ។

– ការបន្ត និងការពង្រឹងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលនៅក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម និងក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

– ការសិក្សា និងការរៀបចំក្របខ័ណ្ឌការងារសម្រាប់ការអនុវត្តភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

**ខ. ការងារអន្តរវិស័យ**

កម្មវិធីជាតិដំណាក់កាលទី២នឹងកំណត់នូវការងារអន្តរវិស័យមួយចំនួនដែលត្រូវបានរៀបចំឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាជាមួយនឹងសមិទ្ធផលរំពឹងទុកនៃសមាសភាគនីមួយៗពាក់ព័ន្ធនឹង៖

– ការងារបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម

– ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

– អភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច។

**១. ការងារបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម**

សមិទ្ធផលរំពឹងទុកនៃការងារនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិជ្រើសរើស និងគ្រប់គ្រងបុគ្គលិក ព្រមទាំងចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយគ្មានការរើសអើង ប្រកាន់ជាតិសាសន៍ សាសនា ភេទ ជនពិការ ក្រុមជនងាយរងគ្រោះផ្សេងទៀត និងបញ្ហាសង្គមផ្សេងៗទៀត។*

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានទទួលស្គាល់ថាជាកម្មវិធីជាតិមួយដែលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចស្ត្រី។ អាស្រ័យហេតុនេះ កម្មវិធីជាតិដំណាក់កាលទី២នឹងបន្តផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតក្នុងការពង្រីកឱ្យកាន់តែទូលំទូលាយ ដើម្បីដាក់បញ្ចូលនូវរាល់បញ្ហាទាំងឡាយពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។ ការងារបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនឹងត្រូវបញ្ជ្រាបទៅគ្រប់សមាសភាគទាំងអស់នៃកម្មវិធីជាតិដំណាក់កាលទី២។

កិច្ចការអាទិភាពមួយចំនួននៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមដែលត្រូវបញ្ជ្រាបទៅក្នុងសមាសភាគនានានៃកម្មវិធីជាតិដំណាក់កាលទី២ រួមមាន៖

– ការរៀបចំ និងអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាដែលឆ្លើយតបនឹងយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។

– ការបង្កើនចំនួន និងអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅក្នុងមុខតំណែងគ្រប់គ្រង មុខតំណែងវិជ្ជាជីវៈ និងភាពជាតំណាងរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

– ការពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការកិច្ចការនារីនិងកុមារឃុំ សង្កាត់ ក្នុងការលើកកម្ពស់ការយកចិត្តទុកដាក់ និងឆ្លើយតបនឹងតម្រូវការយេនឌ័រ ភាពជាអ្នកដឹកនាំរបស់ស្ត្រី ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការផ្តល់សេវាសង្គម និងការកាត់បន្ថយផលប៉ះពាល់នៃអំពើហិង្សាពាក់ព័ន្ធយេនឌ័រនៅតាមសហគមន៍មូលដ្ឋាន។

- ការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងដំណើរការរៀបចំ និងគ្រប់គ្រងធនធានមនុស្ស និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការអនុវត្ត និងតាមដានការអនុវត្តវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចដល់ថ្នាក់ដឹកនាំ ស្តីពីយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។

- ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាប័ន្ន តាមរយៈការដាក់ចេញនូវវិធានការសមធម៌នានា ការពង្រឹង និងការកែលម្អការបែងចែកធនធាន ការផ្ទេរមុខងារ ការរៀបចំផែនការសកម្មភាព ឬកម្មវិធីនានា ដោយផ្តោតលើតម្រូវការរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះ។

- ការពិនិត្យ ការតាមដាន និងការវាយតម្លៃលើការអនុវត្តកម្មវិធីជាតិ និងផែនការអនុវត្តរបស់កម្មវិធីជាតិពាក់ព័ន្ធនឹងការឆ្លើយតបនឹងយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។

**២. ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ**

សមិទ្ធផលរំពឹងទុកនៃការការងារនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិអាចវាយតម្លៃ គ្រប់គ្រង និងឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ដើម្បីគាំទ្រដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន។*

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសកលនឹងមានផលប៉ះពាល់ដល់ការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយផលវិបាកនានាដែលកើតពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទាំងនេះ។ អាស្រ័យហេតុនេះ កិច្ចការជាអាទិភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយដែលត្រូវបញ្ជ្រាបទៅក្នុងសមាសភាគនានានៃកម្មវិធីជាតិដំណាក់កាលទី២ រួមមានៈ

- ការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសិក្សាវាយតម្លៃការរៀបចំផែនការ ការគ្រប់គ្រង និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។

- ការពង្រឹង និងពង្រីកការអនុវត្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅក្នុងផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- ការរៀបចំក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ដើម្បីជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានភាពងាយរងគ្រោះ។

**៣. អភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក**

សមិទ្ធផលរំពឹងទុកនៃការងារនេះគឺ *រដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការបំពេញការងាររបស់ខ្លួន រួមទាំងការងាររដ្ឋបាលផ្ទៃក្នុងរវាងអង្គភាពមួយទៅអង្គភាពមួយទៀត ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។*

ប្រទេសកម្ពុជាកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាយ៉ាងទូលំទូលាយទាំងក្នុងវិស័យឯកជន វិស័យសាធារណៈ និងក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ស្ថានភាពនេះនឹងបន្តរីកចម្រើនបន្ថែមទៀតនៅក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។ អាស្រ័យហេតុនេះ ការងារអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិចនឹងត្រូវបញ្ជ្រាបទៅក្នុងសមាសភាគនានានៃកម្មវិធីជាតិដំណាក់កាលទី២ ដោយផ្តោតទៅលើការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ដែលរួមមានដូចជា៖

- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា
- ការរៀបចំប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមបច្ចេកវិទ្យាព័ត៌មានវិទ្យា
- ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិកក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា។

## VII. ការគ្រប់គ្រង និងការអនុវត្តកម្មវិធីជាតិ

### ១. យន្តការគ្រប់គ្រង និងអនុវត្តកម្មវិធី

កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់របស់រាជរដ្ឋាភិបាលដែលតម្រូវឱ្យមានការយល់ដឹង និងការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្របខ័ណ្ឌអនុវត្តនៃកម្មវិធីជាតិដំណាក់កាលទី២ត្រូវមានភាពបត់បែនសមស្រប ដើម្បីសម្រេចឱ្យបាននូវសមិទ្ធផលនានានៃកម្មវិធីជាតិនេះ។

កត្តាគន្លឹះក្នុងការអនុវត្តកម្មវិធីជាតិប្រកបដោយជោគជ័យគឺការពង្រឹងកិច្ចសហប្រតិបត្តិការ និងការស្រុះស្រួលមូលមតិគ្នាក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅគ្រប់កម្រិត ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប.។ នីតិវិធីបំពេញការងារ និងរចនាសម្ព័ន្ធនានារបស់គ.ជ.អ.ប. ចាំបាច់ត្រូវពិនិត្យ កែសម្រួល និងពង្រឹងឡើងវិញ ដើម្បីជួយដល់ គ.ជ.អ.ប.ក្នុងការដឹកនាំ សម្របសម្រួល និងគ្រប់គ្រងការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២នេះ។ ជាមួយគ្នានេះដែរ កម្មវិធីជាតិដំណាក់កាលទី២នេះនឹងប្រកាន់យកវិធីសាស្ត្រអនុវត្តដោយបើកចំហ ប្រកបដោយបរិយាប័ន្ន និងសមធម៌សង្គម ដើម្បីធានាឱ្យមានការចូលរួម និងការផ្តល់មតិយោបល់នានាពីក្រសួង ស្ថាប័ន សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

កម្មវិធីជាតិដំណាក់កាលទី២នេះនឹងតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលរួមអនុវត្ត និងទទួលខុសត្រូវតាមវិស័យជំនាញ ឬកិច្ចការរបស់ខ្លួននីមួយៗ ដោយមានកិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការចែករំលែកព័ត៌មានគ្នាទៅវិញទៅមក។ អាស្រ័យហេតុនេះ ក្រសួង ស្ថាប័នទាំងនេះត្រូវពិនិត្យមើលឡើងវិញ និងពង្រឹងនូវយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីបង្កើនការទទួលខុសត្រូវ និងជំរុញការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២នេះ។

លេខាធិការដ្ឋានគ.ជ.អ.ប. នឹងបំពេញតួនាទីជាសេនាធិការឱ្យគ.ជ.អ.ប. ក្នុងការសម្របសម្រួល

ការអនុវត្តកម្មវិធីជាតិ ការងារអន្តរវិស័យ ការគាំទ្រផ្នែករដ្ឋបាលនិងការងារលេខាធិការ និងការត្រួតពិនិត្យវាយតម្លៃលើការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។ លេខាធិការដ្ឋានគ.ជ.អ.ប. ក៏នឹងជួយដល់ គ.ជ.អ.ប. ក្នុងការរៀបចំផែនការអនុវត្តតាមដំណាក់កាលនីមួយៗ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តកម្មវិធីជាតិដំណាក់កាលទី២ផងដែរ។

ក្នុងការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍នានា តាមរយៈយន្តការក្រុមការងារបច្ចេកទេសស្របតាមក្របខ័ណ្ឌការងារដែលបានឯកភាពគ្នា។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏នឹងបន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិលនានាក្នុងការពិគ្រោះយោបល់ និងការផ្តល់យោបល់ត្រឡប់លើការរៀបចំ និងការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។

### ២. ការផ្តល់មូលនិធិ

ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តកម្មវិធីជាតិដំណាក់កាលទី២នេះនឹងទទួលបានពីប្រភពថវិកាជាតិ និងអាចមានការចូលរួមផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានា ព្រមទាំងពីប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត។

ការគាំទ្រថវិកាពីរាជរដ្ឋាភិបាលសម្រាប់ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវផ្តល់តាមរយៈផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នអនុវត្តនីមួយៗ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានរៀបចំស្របតាមនីតិវិធីជាធរមាន។

ទំហំ និងបែបផែននៃការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានានឹងត្រូវធ្វើការប៉ាន់ប្រមាណក្នុងអំឡុងពេលនៃការរៀបចំតាក់តែងឯកសារកម្មវិធីជាតិ ដោយធ្វើការតម្រឹមឱ្យបានសមស្របជាមួយនឹងយន្តការនៃការផ្តល់ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និងហិរញ្ញប្បទានពីប្រភពខាងក្រៅ។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តកម្មវិធីជាតិដំណាក់កាលទី២នេះនឹងត្រូវរៀបចំឡើងដោយត្រូវដាក់បញ្ចូលនូវរាល់ថវិកា និងជំនួយមិនមែនថវិកាពីគ្រប់ប្រភពទាំងអស់ដែលរួមចំណែកក្នុងការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២។

### ៣. ការត្រួតពិនិត្យ និងការវាយតម្លៃ

គ.ជ.អ.ប ដោយមានលេខាធិការដ្ឋានជាសេនាធិការនឹងពិនិត្យ និងកែសម្រួលប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ឱ្យកាន់តែមានប្រសិទ្ធភាព មានលក្ខណៈទំនើប មាននិរន្តរភាព និងឆ្លើយតបបញ្ហាអន្តរវិស័យ។ ក្នុងការរៀបចំប្រព័ន្ធនេះត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីបែបផែន និងការទទួលខុសត្រូវសម្រាប់ (១). ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើក្របខ័ណ្ឌលទ្ធផលនៃកម្មវិធីជាតិដំណាក់កាលទី២ ផែនការអនុវត្តតាមដំណាក់កាលនីមួយៗ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ (២). ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តថវិកានិងការផ្តល់សេវាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និង(៣). ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងដាច់ដោយឡែក។ ពាក់ព័ន្ធនឹងបញ្ហានេះ ចាំបាច់ត្រូវពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់អង្គភាព

ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់លេខាធិការដ្ឋានគ.ជ.អ.ប. ក៏ដូចជាយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដទៃទៀត។

លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការក្នុងការគ្រប់គ្រង ប្រមូល និងចងក្រងទិន្នន័យមូលដ្ឋានមួយចំនួនដូចជា ទិន្នន័យមូលដ្ឋានឃុំ សង្កាត់(CDB) ទិន្នន័យគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(SPD) និងទិន្នន័យសម្រាប់ការគ្រប់គ្រង(MIS)ជាដើម។ ទិន្នន័យមូលដ្ឋានទាំងនេះមានសារប្រយោជន៍សម្រាប់ជាប្រព័ន្ធព័ត៌មានក្នុងការត្រួតពិនិត្យ និងការវិភាគរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិដំណាក់កាលទី២នឹងបន្តពង្រឹងការគ្រប់គ្រង ការប្រមូល និងការចងក្រងទិន្នន័យមូលដ្ឋានទាំងនេះ ដោយផ្តល់អាទិភាពខ្ពស់ទៅលើការបង្កើនលទ្ធភាពប្រើប្រាស់ជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រព័ន្ធទិន្នន័យទាំងនេះក៏អាចពង្រីកបន្ថែមទៀតក្នុងការរៀបចំជាឧបករណ៍សាមញ្ញមួយសម្រាប់ការប៉ាន់ស្មានផលិតផលក្នុងស្រុកសរុប(GDP) នៅកម្រិតថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិដំណាក់កាលទី២នឹងកំណត់ស្ថាប័នទទួលខុសត្រូវរយៈពេលវែងសម្រាប់ប្រព័ន្ធទិន្នន័យទាំងនេះដើម្បីជានានិរន្តរភាព។ ការអភិវឌ្ឍបន្ថែមទៀតនៃទិន្នន័យមូលដ្ឋានទាំងនេះនឹងជាកិច្ចការដ៏សំខាន់មួយនៃយុទ្ធសាស្ត្រអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក។

បន្ថែមពីលើការប្រមូលទិន្នន័យបែបបរិមាណ កម្មវិធីជាតិដំណាក់កាលទី២នឹងពិនិត្យកែសម្រួល និងរៀបចំយន្តការទទួលព័ត៌មានត្រឡប់ជាទៀងទាត់អំពីផលប៉ះពាល់នៃការអនុវត្តកម្មវិធីជាតិ។

កម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិ ដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការផ្តល់ការតម្រង់ទិសសម្រាប់ការពង្រឹង និងការកែលម្អការអនុវត្តកម្មវិធីជាតិសម្រាប់ពាក់កណ្តាលអាណត្តិចុងក្រោយ។ នៅឆ្នាំចុងក្រោយនៃកម្មវិធីជាតិនឹងត្រូវធ្វើការវាយតម្លៃបញ្ចប់ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ ដើម្បីផ្តល់អនុសាសន៍សម្រាប់ការបន្តរៀបចំកម្មវិធីជាតិជំហានបន្ទាប់។ ការវាយតម្លៃលើការអនុវត្តកម្មវិធីជាតិខាងលើនេះអាចនឹងមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងឬដៃគូអភិវឌ្ឍន៍។

## VIII. ផែនការសកម្មភាពសម្រាប់រៀបចំកម្មវិធីជាតិដំណាក់កាលទី២ និងការរៀបចំផែនការអនុវត្តដំណាក់កាលដំបូង

ឯកសារទស្សនទាននេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំតាក់តែងឯកសារលម្អិតនៃកម្មវិធីជាតិដំណាក់កាលទី២។ ការរៀបចំសេចក្តីព្រាងកម្មវិធីជាតិដំណាក់កាលទី២នឹងត្រូវដឹកនាំសម្របសម្រួលដោយលេខាធិការដ្ឋានគ.ជ.អ.ប. ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធ និងការស្រុះស្រួលមូលមតិគ្នាជាមួយក្រសួងសំខាន់ៗមួយចំនួនរួមមាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងផែនការ ក្រសួងកិច្ចការនារី និងក្រសួងជំនាញពាក់ព័ន្ធនឹងការផ្ទេរមុខងារ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន។ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងៗទៀតក៏នឹងត្រូវធ្វើការពិគ្រោះយោបល់តាមដំណាក់កាលនៃដំណើរការរៀបចំឯកសារនេះផងដែរ។

ការរៀបចំឯកសារកម្មវិធីជាតិដំណាក់កាលទី២រំពឹងថា នឹងដំណើរការតាមដំណាក់កាលដូចខាងក្រោម៖ (១). ការសិក្សាបច្ចេកទេស និងការរៀបចំតាក់តែងឯកសារតាមសមាសភាគនីមួយៗនៃកម្មវិធីជាតិ (២). ការរៀបចំសេចក្តីព្រាងឯកសារកម្មវិធីជាតិដំណាក់កាលទី២ និងឯកសារផែនការអនុវត្តដំណាក់កាលទីមួយនៃកម្មវិធីជាតិ (៣). ការរៀបចំបញ្ចប់ឯកសារកម្មវិធីជាតិនិងឯកសារផែនការអនុវត្តដំណាក់កាលទីមួយ ព្រមទាំងរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២១។ ពេលវេលា និងកិច្ចការសំខាន់ៗដែលត្រូវសម្រេចបានក្នុងដំណាក់កាលនីមួយៗ មានបង្ហាញក្នុងតារាងដូចខាងក្រោម៖

| ដំណាក់កាល | ពេលវេលា | ចំណុចដៅសំខាន់ៗ |
|---|---|---|
| ១. ការសិក្សាផ្នែកបច្ចេកទេស និងការរៀបចំតាក់តែងសមាសភាគនីមួយៗ | ចុងសប្តាហ៍ទី២ នៃខែកញ្ញា ឆ្នាំ ២០២០ | ✓ លទ្ធផលរំពឹងទុក និងយុទ្ធសាស្ត្រអនុវត្តសំខាន់ៗសម្រាប់សមាសភាគនីមួយៗត្រូវបានឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធ<br>✓ ការឯកភាពគ្នាលើរចនាសម្ព័ន្ធនៃសមាសភាគរបស់កម្មវិធីជាតិដំណាក់កាលទី២<br>✓ ការឯកភាពគ្នាលើក្របខ័ណ្ឌស្ថាប័នសម្រាប់ការអនុវត្ត |
| ២. ការរៀបចំសេចក្តីព្រាងកម្មវិធីជាតិដំណាក់កាលទី២ និងផែនការអនុវត្តដំណាក់កាលទីមួយ | សប្តាហ៍ទី៣នៃខែវិច្ឆិកា ឆ្នាំ ២០២០ | ✓ សេចក្តីព្រាងពេញលេញនៃឯកសារកម្មវិធីជាតិដំណាក់កាលទី២ត្រូវបានរៀបចំ<br>✓ សេចក្តីព្រាងពេញលេញនៃផែនការអនុវត្តដំណាក់កាលទីមួយត្រូវបានរៀបចំ |
| ៣. ការរៀបចំបញ្ចប់ឯកសារកម្មវិធីជាតិដំណាក់កាលទី២ និងផែនការអនុវត្តដំណាក់កាលទី១ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០២១ | ចុងខែធ្នូ ឆ្នាំ ២០២០ | ✓ ឯកសារកម្មវិធីជាតិដំណាក់កាលទី២ និងផែនការអនុវត្តដំណាក់កាលទី១ត្រូវបានរៀបចំបញ្ចប់ និងអនុម័ត<br>✓ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២១ត្រូវបានរៀបចំ |

សកម្មភាពជាក់លាក់ និងក្របខ័ណ្ឌពេលវេលាតាមដំណាក់កាលនីមួយៗខាងលើសម្រាប់ការរៀបចំឯកសារកម្មវិធីជាតិដំណាក់កាលទី២ ឯកសារផែនការអនុវត្តដំណាក់កាលទីមួយ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០២១ នឹងត្រូវកំណត់ដោយលេខាធិការដ្ឋាន គ.ជ.អ.ប.។

***